# គោលដៅរយៈពេលវែង

- ជម្រុញ និងលើកទឹកចិត្ត កុមារីប្រឈមបោះបង់ការសិក្សាអាចបញ្ចប់ការអប់រំកម្រិតមូលដ្ឋាន។
- ផ្តល់ការប្រឹក្សាពីជំនាញវិជ្ជាជីវៈ ដើម្បីឱ្យកុមារីសម្រេចចិត្តបានត្រឹមត្រូវជាមួយនឹងការអប់រំទូទៅ ឬអប់រំបច្ចេកទេសនៅពេលបញ្ចប់គម្រោង។

# គោលដៅរយៈពេលខ្លី

- ធានាថាកុមារីងាយរងគ្រោះចំនួន ១០០ នាក់នៅកម្រិតមធ្យមសិក្សាបឋមភូមិ (៣ឆ្នាំ) មានជម្រើសជីវិតកាន់តែច្រើនសម្រាប់ផែនការអនាគតរបស់ពួកគេ តាមរយៈការផ្តល់អាហារូបករណ៍ និងសកម្មភាពផ្សេងៗនៅតាមសាលារៀនដូចជា៖ ថ្នាក់ភាសាអង់គ្លេស និងការប្រឹក្សាយោបល់។



*រូបភាព៖ កុមារីទទួលបានកញ្ចប់អាហារូបករណ៍ពីគម្រោង*

# អ្នកទទួលផល

| អ្នកទទួលផល | ចំនួន |
|---|---|
| សិស្សស្រីអាហារូបករណ៍ | ១០០ នាក់ |
| សមាជិកគណៈកម្មាការគ្រប់គ្រងអាហារូបករណ៍ | ២៥ នាក់ |
| គ្រូភាសាអង់គ្លេស | ៥ នាក់ |
| គ្រូមុខវិជ្ជា ភាសាខ្មែរ និង គណិតវិទ្យា | ១០ នាក់ |
| នាយក ឬ នាយករង | ៥ នាក់ |
| ឪពុកម្តាយនិង អាណាព្យាបាលសិស្ស | ២០០ នាក់ |
| សមាជិកគណកម្មាការគាំទ្រសាលា | ៣៥ នាក់ |
| **សរុប** | **៣៨០ នាក់** |





*រូបភាព៖ សកម្មភាពការចូលរួមពីការិយាល័យ លោកនាយក លោកគ្រូអ្នកគ្រូ និង អាណាព្យាបាលសិស្ស*

# គម្រោង អប់រំកុមារី ( GEI )

លើកស្ទួយក្មេងស្រីដែលជួបការលំបាក តាមរយៈការអប់រំ




**អាសយដ្ឋានទំនាក់ទំនង**

ការិយាល័យ : សាលាគរុកោសល្យ និងវិក្រឹតការខេត្ត ផ្លូវជាតិលេខ៧ ក្រុងកំពង់ចាម ខេត្តកំពង់ចាម

លេខទូរសព្ទ : 042 941 481 / 042 941 918

**Facebook** : https://www.facebook.com/GEIaction

គេហទំព័រ : www.kapekh.org

# សកម្មភាពសំខាន់ៗរបស់គម្រោង

- ផ្តល់កញ្ចប់អាហារូបករណ៍ (សម្លៀកបំពាក់ កាតាប សៀវភៅ ប៊ិច សម្ភារៈគណិត ដបទឹក ស្បែកជើង)
- ផ្តល់កង់ឱ្យសិស្សដែលនៅឆ្ងាយពីសាលា (១.៥គម)
- ផ្តល់ការបង្រៀនបន្ថែមថ្នាក់ភាសាខ្មែរ គណិតវិទ្យា និង អង់គ្លេស
- ប្រជុំប្រចាំខែជាមួយសិស្សអាហារូបករណ៍
- ប្រជុំអាណាព្យាបាលសិស្ស (មួយឆ្នាំពីរដង)
- ប្រជុំអ្នកពាក់ព័ន្ធ ដូចជា ការិយាល័យ នាយកសាលា គណកម្មការគ្រប់គ្រងអាហារូបករណ៍
- ផ្តល់ថាប់ប្លេត (Tablet) ១០ គ្រឿងដល់សាលាគោលដៅ ដើម្បីជួយសិស្សរៀនបន្ថែមតាមអនឡាញ
- ផ្តល់វគ្គបណ្តុះបណ្តាលស្តីពី "ការប្រឹក្សាអាជីព"
- បង្កើតកម្មវិធី ក្លឹបអានសៀវភៅ ដើម្បីបង្កើនទម្លាប់ និងការចូលចិត្តអានសៀវភៅរបស់សិស្ស
- វាយតម្លៃ និងផលិតវីដេអូឯកសារ នៅចុងឆ្នាំរបស់គម្រោង



រូបភាព៖ គម្រោងអប់រំកុមារីបានផ្តល់កង់សរុប ចំនួន ៧៧ កង់ នៅឆ្នាំ ២០២០ ក្រោមជំនួយ អង្គការ Lotus Outreach Cambodia

# រូបភាពសកម្មភាព




រូបភាព៖ សកម្មភាពសិស្សរៀនភាសាអង់គ្លេស



រូបភាព៖ សិស្សកំពុងអានដោយប្រើ Tablet របស់គម្រោង



រូបភាព៖ សកម្មភាពសិស្សធ្វើចំណាត់ថ្នាក់លើការងារផ្លូវការ និង មិនផ្លូវការ កំឡុងពេលវគ្គបណ្តុះបណ្តាលស្តីពីការប្រឹក្សាអាជីព

# ករណីសិក្សា



ប្អូនស្រី គីមហួយជាសិស្សថ្នាក់ទី៨ នៃអនុវិទ្យាល័យមួយ ក្នុងស្រុកព្រៃឈរ។ នាងរស់នៅក្នុងផ្ទះតូចចាស់មួយធ្វើពីឈើដែលមានសមាជិក៦នាក់ និងនាងជាកូនទី២ ក្នុងចំណោមបងប្អូន៤នាក់។ ឪពុក ជាកសិករ និងម្តាយរបស់នាង ជាកម្មការនីរោងចក្រ។ ។ បងប្រុសរបស់នាងបានឈប់រៀនដោយសារជីវភាពក្រីក្រ។ គីមហួយ ជាសិស្សម្នាក់ក្នុងចំណោមសិស្ស ១០០នាក់ បានទទួលអាហារូបករណ៍ពីអង្គការខេប នៅឆ្នាំ២០១៩។ នាងរំភើប និងត្រេកអរដែលទទួលបានសម្ភារៈសិក្សា និងសម្លៀកបំពាក់ស្អាតបាតទៅសាលារៀនដូចសិស្សដទៃទៀត ។ នាងក៏បានចូលរៀនបំប៉នបន្ថែមថ្នាក់ភាសាអង់គ្លេស ភាសាខ្មែរ និងគណិតវិទ្យាជាមួយគ្រូផងដែរ។ នាងនិយាយថា៖ ខ្ញុំចង់រៀនឱ្យចប់ថ្នាក់ទី ១២ ហើយចង់ក្លាយជាគ្រូបង្រៀន នាពេលអនាគត ។



រូបភាព៖ គីមហួយទទួលបានកង់



រូបភាព៖ គីមហួយខ្ចីសៀវភៅអាន